**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៣ សរណន

# សារាចរណែនាំ

## ស្តីពីការរៀបចំពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំមមែ

## បញ្ចស័ក ព.ស ២៥៤៧ គ.ស ២០០៣

ជារៀងរាល់ឆ្នាំ ប្រជាពលរដ្ឋខ្មែរគ្រប់រូបទូទាំងប្រទេស ទាំងនៅទីក្រុង ទាំងនៅជនបទ និងទាំងបងប្អូនប្រជាពលរដ្ឋកម្ពុជាដែលរស់នៅ ប្រទេសក្រៅ តែងតែប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី ជាប្រពៃណីជាតិរបស់ខ្លួន ក្នុងមនោសញ្ចេតនាសប្បាយរីករាយ ប្រកបដោយ ភក្តីភាព និងសាមគ្គីភាពក្រៃលែង ។

ពិធីនេះ ប្រារព្ធឡើងដើម្បីជាកិច្ចស្វាគមន៍អបអរសាទរការយាងមកដល់នៃទេវតាឆ្នាំថ្មី និងក៏ដូចជាការជូនដំណើរទេវតាឆ្នាំចាស់ ព្រមទាំងសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ថ្វាយព្រះពរចំពោះ**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និង **សម្តេចព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ថ្វាយព្រះពរ ជូនពរថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភារដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការ បុគ្គលិក កម្មករ និយោជិត និងបុព្វការីទាំងឡាយ មានមាតាបិតាជាដើម សំដៅបង្កើនឡើងនូវមនោសញ្ចេតនាគោរព ស្រឡាញ់ជាភាតរភាព សាមគ្គីភាព ស្និទ្ធស្នាល ទទួលពរសព្ទសាធុការពីទេវតាឆ្នាំថ្មី តាមប្រពៃណីជាតិ ក្រោយពីបានបញ្ចប់នូវការងារប្រមូលភោគផលកសិផល និងអនុផលផ្សេងៗនាឆ្នាំចាស់ និងមុនការចាប់ផ្តើមបង្កបង្កើនផលក្នុងឆ្នាំថ្មីដែលនឹងត្រូវដំណើរការ នៅរដូវវស្សានរដូវខាងមុខ បន្ត ទៀត ។

ឆ្នាំនេះ ពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំមមែបញ្ចស័ក ព.ស ២៥៤៧ គ.ស ២០០៣ នឹងត្រូវប្រព្រឹត្តទៅក្នុងរយៈពេល ៣ថ្ងៃគឺ:

- ថ្ងៃចន្ទ ១៣ កើត ខែចេត្រ ត្រូវនឹងថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០០៣ វេលាម៉ោង ១២ថ្ងៃត្រង់ ជាថ្ងៃចូលឆ្នាំ
- ថ្ងៃអង្គារ១៤ កើត ខែចេត្រ ត្រូវនឹងថ្ងៃទី ១៥ ខែ មេសា គ.ស ២០០៣ ជាវារៈវ័នបត ។
- ថ្ងៃពុធ១៥ កើត ខែចេត្រ ត្រូវនឹងថ្ងៃទី ១៦ ខែ មេសា គ.ស ២០០៣ ជាវារៈឡើងស័ក នៅវេលាម៉ោង ១៥ ៥០នាទី និង ២៤ វិនាទី គម្រប់ជាសង្ក្រាន្តបីថ្ងៃ ដោយបរិបូណ៌ និងចូលឆ្នាំ មមែ បញ្ចស័ក តរៀងទៅ។

ដើម្បីបង្កភាពសប្បាយរីករាយ និង រក្សាប្រពៃណីទំនៀមទម្លាប់របស់ជាតិឱ្យបានគង់វង្ស និង ភាពរុងរឿងនោះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដាក់ចេញនូវសារាចរណែនាំដូចខាងក្រោម :

១-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន អង្គភាព រាជធានីភ្នំពេញ និងខេត្ត-ក្រុង វត្តអារាម សាលារៀន រោងចក្រ សហគ្រាស និងគ្រប់គេហដ្ឋាន ត្រូវរៀបចំសំអាត តុបតែងលំអ រំលេចដោយបដា ពាក្យស្លោក ទង់ជាតិ ទង់ផ្កាលានិង រៀបចំគ្រឿងសក្ការបូជា មានផ្កាភ្ញី ទៀនធូបជាដើម ថ្វាយព្រះរតនត្រ័យ និងរៀបចំពលីការដ៏សមរម្យ មាននំចំណីផ្លែឈើជាដើម ទទួលទេវតាឆ្នាំថ្មី ព្រមទាំងត្រូវតុបតែងលំអដោយភ្លើងពណ៌អគ្គិសនី និងនៅតាមជនបទ ចាត់តាំងឱ្យមានការដុតគោម ប្រទីបជ្វាលា ឱ្យបានភ្លឺព្រោងព្រាតនាពេលយប់ ក្នុងរយៈពេលបីថ្ងៃ នៃការចូលឆ្នាំថ្មីប្រពៃណីជាតិ ។

២-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវមានផែនការណែនាំជាក់ស្តែងដល់អង្គភាពក្រោមឱវាទ និងគ្រប់ខេត្ត-ក្រុង បង្កើនកិច្ចការពារថែរក្សាធានាសន្តិសុខ របៀបរៀបរយសណ្តាប់ធ្នាប់សង្គម បង្កបានភាពសប្បាយរីករាយ ធានាសុវត្ថិភាពជូនមហាជន ប្រជាជន មុន ក្រោយនិងក្នុងពេលប្រារព្ធពិធីបុណ្យប្រពៃណីជាតិនេះ ។

៣-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវណែនាំដល់បណ្តាមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ខេត្ត ក្រុង ចាត់តាំងសំដែងសិល្បៈ និងទស្សនីយភាពជូនប្រជារាស្ត្រទស្សនាកំសាន្តតាមទីសាធារណៈ និងបំផុសចលនាប្រជាពលរដ្ឋចូលរួមឱ្យបានផុលផុសក្នុងការចាត់តាំងលេងល្បែងប្រជាប្រិយរបស់ជាតិ ដូចជា បោះឈូង បោះអង្គុញ ទាញព្រ័ត្រ ទាត់សី លាក់កន្សែង រាំកំសាន្តសប្បាយ តាមរមណីយដ្ឋានប្រវត្តិសាស្ត្រនានា តាមវត្តអារាម ទីប្រជុំជន ភូមិ ឃុំ តាមទម្លាប់នៃតំបន់នីមួយៗ ដើម្បីអប់រំនិងបង្ហាញឱ្យយុវជនជំនាន់ក្រោយបានយល់ដឹង និងឃើញច្បាស់ហើយបន្តវេនថែរក្សាឱ្យបានគង់វង្ស ។ រាល់ល្បែងទាំងឡាយដែលនាំឱ្យខាតបង់ អន្តរាយទ្រព្យសម្បត្តិ និងនាំឱ្យមានគ្រោះថ្នាក់ប៉ះពាល់ដល់កិត្តិយស ផ្ទុយពីប្រពៃណីថ្លៃថ្នូររបស់ជាតិ ដូចជា ល្បែងស៊ីសង ល្បែងភ្នាល់ផ្សេងៗ ល្បែងជះទឹកមានពណ៌ ទឹកកខ្វក់ គប់ស្បោងទឹក លាបម្សៅ បាញ់តម្បៀ ទះគក់ដោយដៃ វាយដោយរំពាត់ ដល់អ្នកដំណើរដែល ស្លៀកសំលៀកបំពាក់ថ្មីមានតម្លៃ ត្រូវហាមឃាត់ដាច់ខាត ។

៤-ក្រសួងព័ត៌មាន ត្រូវចាត់តាំងបណ្តាញ វិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ចុះធ្វើសកម្មភាពយកព័ត៌មាន ថតរូបភាពសកម្មភាព ទិដ្ឋភាពជាក់ស្តែងនៃថ្ងៃបុណ្យ ទាំងពិធីសាសនា និងប្រពៃណីជាតិ ដូចជាសកម្មភាពល្បែងប្រជាប្រិយ គ្រប់ប្រភេទតាមតំបន់នីមួយៗ ហើយផ្សព្វផ្សាយឱ្យបានទូលំទូលាយ ។

៥-ក្រសួងធម្មការ និងសាសនា សហការជាមួយអាជ្ញាធរខេត្ត ក្រុង ត្រូវណែនាំដល់អង្គភាពក្រោមឱវាទ រៀបចំពិធីសាសនា តាមវត្តអារាមនីមួយៗឱ្យបានសមស្របតាមប្រពៃណីសាសនា ប្រពៃណីជាតិ ប្រកបដោយបរិយាកាសរីករាយ ដូចជាពិធីពូនភ្នំខ្សាច់ សម្អាតបរិវេណក្នុងវត្ត សម្អាតព្រះពុទ្ធបដិមា ពិធីស្រង់ទឹកព្រះសង្ឃ ស្រង់ទឹកសីលវន្ត សីលវតី មាតាបិតា ចាស់ព្រឹទ្ធាចារ្យជាដើម ។ ត្រូវយកចិត្តទុកដាក់ អំពាវនាវពុទ្ធបរិស័ទឱ្យចាត់តាំងប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនដល់បដិសន្ធិវិញ្ញាណរបស់បងប្អូនជនរួមជាតិ ដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត នៅតាមបូជនីយដ្ឋាន តាមស្តូប តាមវត្តអារាមដែលបានតម្កល់អដ្ឋិធាតុរបស់អ្នកទាំងនោះ ។

៦-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវមានផែនការណែនាំលំអិតសម្រាប់អនុវត្តជាក់ស្តែងនិងត្រូវរៀបចំកម្មវិធីណែនាំដល់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន អង្គភាព ខេត្ត ក្រុង និងសមាគម អង្គការក្រៅរដ្ឋាភិបាលនានា ចាត់តាំងគណៈប្រតិភូ និងបំផុសអំពាវនាវសប្បុរសជន ឱ្យជួយឧបត្ថម្ភអំណោយសម្ភារៈ ថវិកា ចុះសួរសុខទុក្ខអ្នកមានជម្ងឺរបួស កំពុងសំរាកព្យាបាលនៅតាមមន្ទីរពេទ្យនានា និងអ្នក ពិការ កុមារកំព្រានៅតាមមណ្ឌលនានា និងចាស់ព្រឹទ្ធាចារ្យឥតទីពឹង ដើម្បីជាការលើកទឹកចិត្ត និងបង្កើនស្មារតីជួយគ្នាទៅវិញ ទៅមក ក្នុងគ្រាមានទុក្ខលំបាក ក៏ដូចជាក្នុងឱកាសសប្បាយរីករាយ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹមថា គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន គ្រប់ស្ថាប័ន អង្គភាព ខេត្ត ក្រុង ទូទាំងប្រទេស នឹងអនុវត្តតាមស្មារតីនៃសារាចរណែនាំនេះ សំរេចបានផលល្អប្រសើរ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមេសា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន និងខេត្ត ក្រុង
  "ដើម្បីសហការអនុវត្ត"
- ឯកសារ- កាលប្បវត្តិ

# ពា ក្យ ស្លោ ក

## សំរាប់ប្រើប្រាស់ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំមមែ
## ចត្វាស័ក ព.ស ២៥៤៧ គ.ស ២០០៣

១- សួស្តី ឆ្នាំថ្មី !

២- សូមជូនពរឆ្នាំថ្មី ឆ្នាំមមែ សិរីសួស្តីជ័យមង្គល និងវិបុលសុខគ្រប់ប្រការ

៣- សូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខ ដ៏ឧត្តមប្រសើរ ក្នុងឱកាសចូលឆ្នាំថ្មីឆ្នាំមមែ

៤- ឆ្នាំថ្មី ភារកិច្ចថ្មី ជ័យជំនះថ្មី !

៥- សូមថ្វាយព្រះពរ សម្តេចឪ សម្តេចម៉ែ សូមមានព្រះជន្មាយុយឺនយូរ

៦- ជយោ ! សម្តេចព្រះបិតាបង្រួបបង្រួម និងផ្សះផ្សាជាតិ

៧- ជយោ ! ព្រះរាជាណាចក្រកម្ពុជា

៨- ជាតិ សាសនា ព្រះមហាក្សត្រ

៩- ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍

១០- ជយោ ! រាជរដ្ឋាភិបាលសេដ្ឋកិច្ច

១១- សន្សំសំចៃ ជីស្នេហាជាតិ

១២- ស្វាគមន៍ ឆ្នាំមមែ បញ្ចស័ក ព.ស ២៥៤៧

១៣- ជយោ ! ឆ្នាំមមែ បញ្ចស័ក ព.ស ២៥៤៧

១៤- ជយោ ! ឆ្នាំ២០០៣ ឆ្នាំពង្រឹងគ្រឹះលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន